ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ.......✓..........

# សេចក្តីថ្លែងការណ៍
# អ្នកនាំពាក្យក្រសួងការពារជាតិ

នាថ្មីៗនេះ សារព័ត៌មានបរទេសមួយចំនួន បានចម្លងគ្នា ផ្សព្វផ្សាយដោយគ្មានប្រភពច្បាស់លាស់ថា ប្រទេសដទៃមានបំណងប្រើប្រាស់ទឹកដីកម្ពុជាធ្វើមូលដ្ឋានយោធា សំចតនាវាចម្បាំង ហើយកម្ពុជាកំពុងស្ថិតនៅចំណុចកណ្តាល នៃសង្គ្រាមត្រជាក់រវាងចិន និងអាមេរិកជាដើម។

នេះគ្រាន់តែជាដំណឹងក្លែងក្លាយ (Fake News) ដែលក្រុមបរទេសមួយចំនួន ព្យាយាមផ្សព្វផ្សាយចោទប្រកាន់មកលើកម្ពុជាក្នុងចេតនាអាក្រក់ ញុះញង់ ដើម្បីបំភាន់សាធារណជនជាតិ-អន្តរជាតិ និងជាចេតនាបំផ្លាញដល់ ឯករាជ្យ ភាពអព្យាក្រឹតអចិន្ត្រៃយ៍ របស់កម្ពុជាតែប៉ុណ្ណោះ។

ព្រះរាជាណាចក្រកម្ពុជា ដែលជារដ្ឋឯករាជ្យ អព្យាក្រឹតអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ដូចមានចែងក្នុងមាត្រា៥៣ថ្មី នៃរដ្ឋធម្មនុញ្ញ។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងថែរក្សា សុខសន្តិភាព ជូនប្រជាពលរដ្ឋ និងទប់ស្កាត់ការប៉ុនប៉ងទាំងឡាយដែលអូសទាញនាំឱ្យប្រទេសធ្លាក់ទៅក្នុងសង្គ្រាមជាថ្មី ដើម្បីធ្វើយ៉ាងណាបន្តការអភិវឌ្ឍជាតិ ឱ្យមានការរីកចម្រើនទៅមុខ ដូច្នេះហើយកម្ពុជាមិនបានចូលរួមជាមួយ សង្គ្រាមត្រជាក់ណាមួយ ឬអនុញ្ញាតឱ្យបរទេសណាមួយ ប្រើប្រាស់ទឹកដីរបស់ខ្លួនធ្វើមូលដ្ឋានយោធា ដូចដែលព័ត៌មានក្លែងក្លាយទាំងនោះបានផ្សាយចោទប្រកាន់ទេ។

អ្នកនាំពាក្យក្រសួងការពារជាតិ សូមប្រកាសច្រានចោលទាំងស្រុងនូវការចុះផ្សាយរបស់ សារព័ត៌មាន Asia Times ដែលលាបពណ៌ ញុះញង់ ធ្វើឱ្យប៉ះពាល់ដល់ កេត្យានុភាពវិស័យយោធា និង អព្យាក្រឹតអចិន្ត្រៃយ៍របស់កម្ពុជា ហើយសូមឱ្យបញ្ឈប់ការផ្សាយដោយគ្មានប្រភពច្បាស់លាស់នេះតទៅទៀត៕

ថ្ងៃសៅរ៍ ១០កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨